ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៣៥/១៨-ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី
កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **ឈើវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **គង់ ផល្លះ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី**

អាសយដ្ឋាន ៖ ភូមិត្រពាំងទូល សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩២ ៩៣៥ ៧៧៥ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមប្រជុំមុនសវនាការ ៖

| | |
|---|---|
| ១- លោក ឡុង ផល្លី | ធនធានមនុស្ស |
| ២- លោក កង តារារុធ | មេធាវី |
| ៣- កញ្ញា សុខ សុជាវត្តី | ជំនួយការមេធាវី |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី**

អាសយដ្ឋាន ៖ ភូមិត្រពាំងទូល សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១០ ៩៣៤ ៩៤៤ ទូរសារ ៖ គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥.២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Toul Kork, Phnom Penh + Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org + Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតចូលរួមប្រជុំមុនសវនាការ ៖

| | | |
|---|---|---|
| ១- | លោក តែប តុន | ប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករកម្ពុជា |
| ២- | លោក យន់ សុខន | កម្មករ |
| ៣- | កញ្ញា ចក់ ខែម | កម្មករ |
| ៤- | លោក វង់ វៃយីន | កម្មករ |
| ៥- | កញ្ញា សំរិត ឌីណា | កម្មករ |
| ៦- | កញ្ញា យ៉ង់ សឿន | កម្មករ |
| ៧- | កញ្ញា ណង់ សាវី | កម្មករ |
| ៨- | កញ្ញា ស សោភាង | កម្មករ |
| ៩- | លោកស្រី អាត ស៊ីណាង | កម្មករ |
| ១០- | លោកស្រី ហ៊ឹម សុភ័ក្រ | កម្មករ |
| ១១- | កញ្ញា ឃិន សុភ័ក្ត | កម្មករ |
| ១២- | កញ្ញា យឹម សុខហៀង | កម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ភាគីកម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនទូទាត់បញ្ចប់កិច្ចសន្យាចាស់ជាមុនសិន បើសិនជាក្រុមហ៊ុនផ្លាស់ប្តូរទីតាំង ឬប្តូរឈ្មោះ។ ដោយឡែក ភាគីក្រុមហ៊ុនបានបញ្ជាក់ថា ក្រុមហ៊ុនបានទូទាត់បញ្ចប់កិច្ចសន្យាជូនបងប្អូនកម្មករនិយោជិតរួចរាល់ហើយ ដោយអនុវត្តតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជាមួយគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជីមលី (ខេមបូឌា) ខូអិលធីឌី លេខ

THE ARBITRATION COUNCIL

៧៥៧ ក.ប/អក/វក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨។

**សវនាការ និង សន្ទេបនីតិវិធី**

**ទីកន្លែងជួបប្រជុំមុនសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល "ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ" ។

**កាលបរិច្ឆេទប្រជុំមុនសវនាការ** ៖ ថ្ងៃព្រហស្បតិ៍ ៤កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ១៤ និង ០០ នាទី រសៀល ។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត តាមរយៈទូរសព្ទ ស្តីពីការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនទូទាត់បញ្ចប់កិច្ចសន្យាការងារចាស់ជាមុនសិន ករណីក្រុមហ៊ុនផ្លាស់ប្តូរទីតាំង ឬប្តូរឈ្មោះ។ ក្រោយពីបានទទួលបណ្តឹងនេះ នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងាររួមនេះ ជាបន្តបន្ទាប់ ទៅតាមនីតិវិធីច្បាប់ និងបានធ្វើការផ្សះផ្សាលើកចុងក្រោយ នៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨ លើចំណុចវិវាទចំនួន ១ ចំណុច ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជាចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៨ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជីម លី (ខេមបូឌា) ភីធីអ៊ី លេខ ៧៥៧ ក.ប/អក/វក ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៨។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨។ នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ លើករណីមិនសះជាចំនួន ១ ចំណុចនេះ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ នៅថ្ងៃដដែលនេះ បន្ទាប់ពីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានចេញលិខិតអញ្ជើញភាគីទាំងពីរ ចូលរួមសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក៏បានទទួលលិខិតមួយច្បាប់របស់ក្រុមហ៊ុន ជីម លី (ខេមបូឌា) ភីធីអ៊ី អិលធីឌី ចុះនៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីសំណើសុំឱ្យក្រុមប្រឹក្សាអាជ្ញា-កណ្តាលចេញសេចក្តីបញ្ជាដើម្បីផ្អាកកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ជីម លី។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០០២/១៨ កបអ. ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ឱ្យផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មរបស់កម្មករនិយោជិតនៃ ក្រុមហ៊ុន ជីម លី (ខេមបូឌា) ភីធីអ៊ី អិលធីឌី រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីរសៀលថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ តទៅ តាមវេនរបស់ខ្លួន។

បន្ទាប់ពីចេញសេចក្តីបញ្ជានេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលដំណឹងតាមរយៈលេខាធិការដ្ឋានក្រុម-ប្រឹក្សាអាជ្ញាកណ្តាលថា កម្មករនិយោជិតមិនបានត្រឡប់ចូលធ្វើការតាមសេចក្តីបញ្ជានោះទេ ហើយនៅតែបន្តធ្វើកូដកម្មដដែល។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំ

មុនសវនាការអាជ្ញាកណ្តាលនាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ វេលាម៉ោង ១៤ និង ០០ នាទី រសៀល តាមរយៈទូរសព្ទ នៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៨។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីនិយោជក និងភាគីតំណាងកម្មករនិយោជិតមានវត្តមាន តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ នៅថ្ងៃកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្តាល ភាគីទាំងពីរទទួលស្គាល់ថា មានកម្មករនិយោជិតដែលបានចូលធ្វើការងារវិញ និងនៅមានកម្មករនិយោជិតមួយចំនួនដែលមិនព្រមចូលធ្វើការវិញដែរ។ ជារួម ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថានៅមានកម្មករនិយោជិតមួយចំនួននៅបន្តធ្វើកូដកម្ម ដោយមិនព្រមធ្វើការ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ជីម លី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជាដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ជីម លី។

២- លិខិតចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ របស់ក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អែលធីឌី គោរពជូន លោកប្រធានលេខាធិការដ្ឋាន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីរបាយការណ៍ស្តីពីកូដកម្មរបស់កម្មករនៃរោងចក្រ ជីម លី។

៣- កំណត់ហេតុ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ រវាងតំណាងក្រុមហ៊ុន និងតំណាងសហជីពទាំង៣។

៤- កិច្ចព្រមព្រៀងរវាងតំណាងក្រុមហ៊ុនកាត់ដេរ ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី និងតំណាងសហជីពចលនាកម្មករប្រចាំក្រុមហ៊ុន ជីមលី ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងប្រតិភូចរចារដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អែលធីឌី គោរពជូន លោកប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីជូនដំណឹងស្តីពីសភាពការណ៍នៅក្នុងក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អែលធីឌី។

២- លិខិតចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ របស់តំណាងប្រតិភូចរចារ គោរពជូនលោក តែប តុន ប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ ស្តីពីស្នើសុំលោកប្រធានអញ្ជើញចូលរួមដើម្បីជួយអមយើងខ្ញុំ ក្នុងសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល (សំណុំរឿងលេខ ០៣៥/១៨ ដើម្បីដោះស្រាយវិវាទការងាររួមរបស់បងប្អូនកម្មករ ជាមួយ និងក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អែលធីឌី។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

THE ARBITRATION COUNCIL

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី លេខ ៧៥៧ ក.ប/អក/វក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៅក្រុមហ៊ុន ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី លេខ ២៧/១៨ ក.ប/អក/ល.ប.វ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៣២ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨។

២- លិខិតអញ្ជើញភាគីនិយោជិតចូលរួមសវនាការ លេខ ២៣៣ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨។

៣- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ០០២/១៨កបអ. ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨។

**អង្គហេតុ ៖**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលចែងថា ៖ "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម* "។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការនេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើ

ឡុកអៅ។ (*សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៥៩/០៦-សាង វ៉ូ, លេខ ៣៩/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩ &១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាណូ, លេខ ១០៤/១៣-សាប្រ៊ីណា (ខេមបូឌា), លេខ ៣២២/១៤-ជីមលី (ខេមបូឌា) ភីធីអ៊ី អិលធីឌី, លេខ ០៧១/១៥-អ៊ុម វ៉េ កាត់ដេរ អន្តរជាតិ សាខាកំពង់ឆ្នាំង និងលេខ ០២១/១៦-ស្តារឡៃថ៍ អ៊ីភែរីល មេនូហ្វេកឆឺរីង)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងសំណុំរឿងខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ នៅក្នុងនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល កម្មករនិយោជិតបាននិងកំពុងតែធ្វើកូដកម្ម ហើយក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលសំណើពីតំណាងនិយោជកឱ្យចេញសេចក្ដីបញ្ជា ដើម្បីផ្អាកកូដកម្មរបស់កម្មករនិយោជិត។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបញ្ជា លេខ ០០២/១៨ កបអ. ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ឱ្យកម្មករនិយោជិតបញ្ឈប់កូដកម្ម និងចូលធ្វើការធម្មតា និងបានអញ្ជើញភាគីទាំងពីរមកចូលរួមកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ ដើម្បីសួរបញ្ជាក់ពីករណីកូដកម្មនេះ។ នៅក្នុងកិច្ចប្រជុំមុនសវនាការអាជ្ញាកណ្ដាល ភាគីនិយោជក និងតំណាងកម្មករនិយោកជិត បានលើកឡើងថា បច្ចុប្បន្ន គឺមានកម្មករនិយោជិតដែរបានចូលធ្វើការវិញ និងនៅមានកម្មករនិយោជិតមួយចំនួនដែលមិនព្រមចូលធ្វើការ ហើយនៅតែទាមទារឱ្យនិយោជកទូទាត់ប្រាក់បំណាច់ផ្ដាច់កិច្ចសន្យាការងារដដែល។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា កូដកម្មនៅតែបន្ត។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនអាចបន្តនីតិវិធី និងដំណើរការសវនាការបានទេ។

ហេតុនេះ យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីដូចតទៅ៖

**សម្រេច**

- បញ្ចប់ដំណើរការអាជ្ញាកណ្ដាលក្នុងសំណុំរឿងលេខ ០៣៥/១៨-ជីម លី (ខេមបូឌា) ភីធីអ៊ី អិលធីឌី។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ៖ **ឈឹម តិរម្យ**

ហត្ថលេខា៖ -----------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ៖ **អន ណាន**

ហត្ថលេខា៖ -----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា ៖ ----------------